ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
**លេខៈ ១២៦/២៣ អអរ**

# សេចក្ដីប្រកាសព័ត៌មាន
## លទ្ធផលនៃសន្និសីទសារព័ត៌មានស្ដីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ"

នាព្រឹកថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្ដីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ»** ដែលមានវាគ្មិនចូលរួមគឺៈ

- **ឯកឧត្ដម អ៊ុំ រាត្រី អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ**
- **មន្ទីរអង្គភាពជំនាញជុំវិញរដ្ឋបាលខេត្តបន្ទាយមានជ័យ**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យ ដែលរដ្ឋបាលខេត្តបន្ទាយមានជ័យ ខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

## I. ស្ថានភាពទូទៅ

ខេត្តបន្ទាយមានជ័យ បែងចែកចេញជា ក្រុង២ ស្រុក៧ ឃុំ៥៥ និងភូមិចំនួន៦៥៩ ដែលមានប្រជាពលរដ្ឋរស់នៅសរុប ៨០០.១៨៨នាក់ ស្មើនឹង ១៩៨.៩២៦គ្រួសារ ដោយក្នុងនោះ ប្រជាពលរដ្ឋប្រកបរបរកសិកម្ម៨៥% អាជីវកម្ម និងពាណិជ្ជកម្ម១០% និងប្រកបរបរផ្សេងៗ៥%។ ទំហំសេដ្ឋកិច្ចខេត្តមានចំនួនប្រមាណ ១.១៥៤លានដុល្លារអាមេរិក ស្មើនឹង ៤,៣% នៃសេដ្ឋកិច្ចជាតិ ខណៈដែលចំណូលជាមធ្យមរបស់មនុស្សម្នាក់ស្មើនឹង ១.៣៦៧ដុល្លារអាមេរិក។

## II. សមិទ្ធផលការងារ

ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ(២០១៨-២០២២) សមិទ្ធផលការងារសំខាន់ៗ ដែលសម្រេចបានរួមមាន៖

- **វិស័យគាំពារសង្គម៖** រដ្ឋបាលខេត្ត បានអនុវត្តនូវគោលនយោបាយគាំពារសង្គរបស់រាជរដ្ឋាភិបាល ដែលបានរួមចំណែកក្នុងការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ កាត់បន្ថយអត្រាភាពក្រីក្រ ដោយសម្រេចបាននូវការឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងរងគ្រោះដោយសារជំងឺកូវីដ-១៩ ចំនួន ៣៣.៧១៥គ្រួសារ ចំណាយថវិកា ១២១.៥២២.៤៣៥.៨០០រៀល ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ សរុបចំនួន ៩.៤៣០នាក់ អស់ទឹកប្រាក់ ៤.៣២៩.២៨០.០០០រៀល និងគ្រួសារងាយរងហានិភ័យដោយសម្ពាធអតិផរណាចំនួន ១៥.២៩៦គ្រួសារ ចំណាយថវិកា ២.៣១១.៥៩៨.៨០០រៀល និងទឹកជំនន់ ១៩.៧២៣គ្រួសារ ចំណាយថវិកា ៣.១៩១.២៤៨.០០០រៀល។ ជាមួយគ្នានេះ រដ្ឋបាលខេត្តបានរៀបចំផ្ដល់នូវដីសម្បទានសង្គមកិច្ច ជូនអតីតយុទ្ធជន និងប្រជាពលរដ្ឋសរុប ១.៨១៩,៦១ហិកតា។
- **វិស័យកសិកម្ម៖** ជាខេត្តជង្រុកស្រូវនៃព្រះរាជាណាចក្រកម្ពុជា ដែលមានផ្ទៃដីដាំដុះស្រូវសរុប ៣០៥.០៣៥ហិកតា ដែលទទួលបានបរិមាណផលជាមធ្យមចន្លោះពី ៩០ម៉ឺន ទៅ១លានតោន ក្នុងមួយឆ្នាំៗ ក្រៅពីនោះ មានដំណាំឧស្សាហកម្ម ដែលមានផ្ទៃដីសរុប ១២២.៧៩២ ហិកតា (ដំឡូងមី ស្វាយចន្ទី ពោតក្រហម អំពៅ សណ្ដែក ដំណាំបន្លែ) និងដំណាំរួមផ្សំផ្សេងទៀត ដែលមានផ្ទៃដី ៥.៧៣៥ហិកតា ដែលទិន្នផលទទួលបានមានការកើនឡើងជាលំដាប់។ ជាមួយគ្នានោះ ទូទាំងខេត្ត មានប្រព័ន្ធធារាសាស្ត្រ ដែលទ្រទ្រង់លើការងារកសិកម្ម ចំនួន ៨៧ប្រព័ន្ធ។
- **ការងារសន្តិសុខ សណ្តាប់ធ្នាប់ និងការផ្តល់សេវាសាធារណៈ៖** ទាំងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ បានរួមគ្នាយកចិត្តទុកដាក់ និងមានទំនួលខុសត្រូវខ្ពស់ ក្នុងការរក្សានូវសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ មានលក្ខណៈល្អប្រសើរ តាមរយៈការអនុវត្តនយោបាយភូមិ-ឃុំមានសុវត្ថិភាព បទល្មើសគ្រប់ប្រភេទ ត្រូវបានបង្ក្រាប និងកាត់បន្ថយបានជាបន្តបន្ទាប់ ជាពិសេស សន្តិសុខព្រំដែន ដោយរក្សាបាននូវទំនាក់ទំនងកិច្ចសហប្រតិបត្តិការល្អជាមួយខេត្តជាប់ព្រំដែន តាមរយៈការជួបជុំពិភាក្សា និងផ្លាស់ប្ដូរព័ត៌មានទៅវិញទៅមក។ ជាមួយគ្នានេះ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ តាមរយៈពង្រឹង និងពង្រីកនូវយន្តការច្រកចេញ

ចូលតែមួយ ទៅដល់គ្រប់បណ្តាឃុំ-សង្កាត់ទាំងអស់ នៅទូទាំងខេត្ត។ យន្តការនេះ បានផ្តល់សេវាជូនប្រជាពលរដ្ឋសរុប ២១៤.៣៧០សេវា ទទួលបានចំណូលសរុប ១៧.៩២៦.០៤៨.៩០០រៀល។

- **ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ៖** រដ្ឋបាលខេត្ត បានពង្រីកនូវការកសាង និងជួសជុលជាបន្តបន្ទាប់ នូវបណ្តាញផ្លូវគមនាគមន៍ទាំងនៅទីជនបទ ទីប្រជុំជន ក្នុងគោលដៅតភ្ជាប់ពីទីរួមខេត្តទៅគ្រប់បណ្តាភូមិ -ឃុំទាំងអស់។ ជាមួយគ្នានេះ បានរៀបចំប្រព័ន្ធលូរំដោះទឹក ស្ថានីយ៍ប្រព្រឹត្តកម្មទឹកស្អុយ និងបានបំពាក់ភ្លើងបំភ្លឺតាមដងផ្លូវ។ ចំពោះការងារផ្គត់ផ្គង់អគ្គិសនី និងបណ្តាញទឹកស្អាត ខេត្តទទួលបាននូវការរីកចម្រើនយ៉ាងខ្លាំង ដោយបណ្តាញទឹកស្អាតចំនួន ៧៦% និងអគ្គិសនីចំនួន ៩៩% ត្រូវបានចែកចាយទៅដល់ប្រជាពលរដ្ឋសម្រាប់បម្រើនូវការរស់នៅប្រចាំថ្ងៃ។
- **វិស័យទេសចរណ៍៖** តាមរយៈតំបន់ប្រវត្តិសាស្ត្រ វប្បធម៌ និងរមណីយដ្ឋានជាច្រើនទៀត ព្រមទាំងការបម្រើសេវាកម្មប្រកបដោយភាពកក់ក្តៅ និងគុណភាព ដែលជាសក្តានុពលទាក់ទាញភ្ញៀវទេសចរ ដោយខេត្តទទួលបានភ្ញៀវមកទស្សនា និងសម្រាកលំហែ សរុបប្រមាណ ៦.០០៦.០៧១នាក់។ តាមរយៈវិស័យនេះ បានផ្តល់អត្ថប្រយោជន៍ដល់ការអភិវឌ្ឍសហគមន៍ បង្កើតការងារ និងបង្កើនប្រាក់ចំណូលជូនប្រជាពលរដ្ឋផងដែរ។

## III. ទិសដៅការងារបន្ត

រដ្ឋបាលខេត្តបន្ទាយមានជ័យ ប្តេជ្ញាបន្តជំរុញនូវការផ្តល់សេវាសាធារណៈ ឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព ទាន់ពេលវេលា និងបន្តជំរុញការផ្សព្វផ្សាយគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ក្នុងន័យទប់ស្កាត់ និងបង្ការបទល្មើស អំពើហិង្សាគ្រប់រូបភាព។ បន្តជំរុញនូវការងារកសិកម្មតាមរយៈយន្តការអប់រំបច្ចេកទេស ដីតិចទទួលបានផលច្រើន និងទាក់ទាញនូវវិនិយោគិនបន្ថែមទៀត។ បន្តថែរក្សាធនធានធម្មជាតិ តំបន់អភិរក្សព្រៃឈើ សត្វព្រៃ ជលផល តំបន់ការពារធម្មជាតិ ព្រៃលិចទឹក ដែលចូលរួមបង្ការ និងទប់ស្កាត់បម្រែបម្រួលអាកាសធាតុ និងគ្រោះធម្មជាតិនានា។ ខិតខំបង្កើន និងពង្រឹងការគ្រប់គ្រងដីធ្លី ដោយជំរុញការចុះបញ្ជីដីធ្លី ផ្តល់បណ្ណកម្មសិទ្ធិជូនប្រជាជនជានាបាននូវការប្រើប្រាស់ដីដោយស្របច្បាប់ កាត់បន្ថយទំនាស់ដីធ្លី បង្កើនចំណូលសេដ្ឋកិច្ចគ្រួសារ និងសង្គមជាតិទាំងមូល៕

ថ្ងៃអង្គារ ៧កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣